រាជរដ្ឋាភិបាលកម្ពុជា
ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
Council for the Development of Cambodia


ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia
ជាតិ សាសនា ព្រះមហាក្សត្រ
Nation-Religion-King

*ថ្ងៃសុក្រ ២រោច ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩*
*រាជធានីភ្នំពេញ ថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០២៥*

# សេចក្តីប្រកាសព័ត៌មាន

## គម្រោងវិនិយោគចំនួន២៩ ក្នុងទំហំទុនវិនិយោគសរុបប្រមាណ ១,៤ប៊ីលានដុល្លារអាមេរិក ត្រូវបានចុះបញ្ជីដោយគណៈកម្មាធិការវិនិយោគកម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងខែតុលា ឆ្នាំ២០២៥

ក្នុងខែតុលា ឆ្នាំ២០២៥ គណៈកម្មាធិការវិនិយោគកម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានសម្រេចចុះបញ្ជីគម្រោងវិនិយោគសរុបចំនួន**២៩គម្រោង** ក្នុងទំហំទុនវិនិយោគសរុបប្រមាណ**១,៤ប៊ីលានដុល្លារអាម៉េរិក** និងអាចបង្កើតការងារបានប្រមាណ**២៥ពាន់កន្លែង**។ ក្នុងចំណោមគម្រោងវិនិយោគសរុប គម្រោងវិនិយោគដែលមានទីតាំងស្ថិតនៅក្រៅតំបន់សេដ្ឋកិច្ចពិសេសមានចំនួន ១៨គម្រោង និងគម្រោងវិនិយោគដែលមានទីតាំងស្ថិតនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសមានចំនួន ១១គម្រោង។ ក្នុងរយៈពេល១០ខែនៃឆ្នាំ២០២៥នេះ គ.វ.ក. បានសម្រេចចុះបញ្ជីគម្រោងវិនិយោគចំនួន **៥៧៥គម្រោង** ក្នុងទំហំទុនវិនិយោគសរុបប្រមាណ **៩,២**ប៊ីលានដុល្លារអាម៉េរិក គឺគម្រោងវិនិយោគមានការកើនឡើងចំនួន **២២៩គម្រោង** ស្មើនឹងប្រមាណ **៦៦%** ខណៈទុនវិនិយោគមានការកើនឡើងប្រមាណជិត **៣,៧**ប៊ីលានដុល្លារអាម៉េរិក ស្មើនឹងប្រមាណ **៦៧%** បើប្រៀបធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២៤ ដែលមានគម្រោងវិនិយោគត្រឹមតែ ៣៤៦គម្រោង ក្នុងទំហំទុនវិនិយោគប្រមាណ ៥,៥ប៊ីលានដុល្លារអាម៉េរិក។ ជាការកត់សម្គាល់ត្រឹមតែរយៈពេល១០ខែ គ.វ.ក បានចុះបញ្ជីគម្រោងវិនិយោគលើសការចុះបញ្ជីគម្រោងវិនិយោគពេញមួយឆ្នាំ២០២៤ រហូតដល់ទៅ **១៦១គម្រោង**។

គម្រោងវិនិយោគដែលមានភាពលេចធ្លោប្រចាំខែតុលា ឆ្នាំ២០២៥ មានដូចខាងក្រោម៖

## ក. ក្រៅតំបន់សេដ្ឋកិច្ចពិសេស

### ហេដ្ឋារចនាសម្ព័ន្ធ

**គម្រោងវិនិយោគសាងសង់ និងប្រតិបត្តិការព្រែកជីកហ្វូណនតេជោ**

- **ទីតាំង៖** តាមបណ្តោយខេត្តកណ្តាល តាកែវ កំពត និងកែប
- **ទំហំទុនវិនិយោគប្រមាណ៖** ១,២ប៊ីលានដុល្លារអាម៉េរិក
- **ការបង្កើតការងារ៖** ៣.១៩៩កន្លែង។

**គម្រោងវិនិយោគបង្កើតមន្ទីរពេទ្យចំនួន២២១គ្រែ**

- **ទីតាំង៖** ខណ្ឌមានជ័យ រាជធានីភ្នំពេញ
- **ទំហំទុនវិនិយោគប្រមាណ៖** ៧៦លានដុល្លារអាម៉េរិក
- **ការបង្កើតការងារ៖** ៧៤១កន្លែង។

### ឧស្សាហកម្ម

**គម្រោងវិនិយោគបង្កើតរោងចក្រផលិតក្រណាត់ និងអំបោះគ្រប់ប្រភេទ**

- **ទីតាំង៖** ស្រុកកៀនស្វាយ ខេត្តកណ្តាល
- **ទំហំទុនវិនិយោគប្រមាណ៖** ៥០លានដុល្លារអាម៉េរិក
- **ការបង្កើតការងារ៖** ១.៨២០កន្លែង។

## ខ. ក្នុងតំបន់សេដ្ឋកិច្ចពិសេស

### ឧស្សាហកម្ម

**គម្រោងវិនិយោគបង្កើតរោងចក្រផលិតការ៉ូឈើគ្រប់ប្រភេទ**

- **ទីតាំង៖** តំបន់សេដ្ឋកិច្ចពិសេស កោះកុង បេជាង ស្ថិតនៅខេត្តកោះកុង
- **ទំហំទុនវិនិយោគប្រមាណ៖** ១៦លានដុល្លារអាម៉េរិក
- **ការបង្កើតការងារ៖** ២៨៥កន្លែង។

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
COUNCIL FOR THE DEVELOPMENT OF CAMBODIA

# គម្រោងវិនិយោគក្នុង ខែតុលា ឆ្នាំ២០២៥

ដែលត្រូវបានអនុម័តដោយគណៈកម្មាធិការវិនិយោគកម្ពុជា
នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

**គម្រោងវិនិយោគ**
**២៩** (១១ គម្រោង ក្នុងតំបន់សេដ្ឋកិច្ចពិសេស)

**ទុនវិនិយោគ**
**១,៤** ប៊ីលាន ដុល្លារអាម៉េរិក

**បង្កើតការងារ**
**~២៥៣ពាន់** កន្លែង

## ទុនវិនិយោគតាមវិស័យ (គិតជាដុល្លារអាម៉េរិក)




## ប្រភពទុនវិនិយោគឈានមុខ

| | |
|---|---|
| 1. ចិន | ៤៩,២៤% |
| 2. កម្ពុជា | ៤៧,៦៨% |
| 3. សហរដ្ឋអាម៉េរិក | ១,៣៣% |
| 4. សិង្ហបុរី | ០,៨% |
| 5. ម៉ាឡេស៊ី | ០,៥៧% |
| 6. អូស្ត្រាលី | ០,៣៩% |

## របាយគម្រោងវិនិយោគនៅតាមបណ្ដារាជធានី-ខេត្ត




**កំណត់សម្គាល់**
- # ចំនួនគម្រោង
- ៦+
- ១-៥
- មិនមាន

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
COUNCIL FOR THE DEVELOPMENT OF CAMBODIA

# គម្រោងវិនិយោគចាប់ពី ខែមករា ដល់ខែតុលា ឆ្នាំ២០២៥

ដែលត្រូវបានអនុម័តដោយគណៈកម្មាធិការវិនិយោគកម្ពុជា
នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

**គម្រោងវិនិយោគ**
**៥៧៥** (២១៨ គម្រោង ក្នុងតំបន់សេដ្ឋកិច្ចពិសេស)

**ទុនវិនិយោគ**
**៩,២** ប៊ីលាន ដុល្លារអាម៉េរិក

**បង្កើតការងារ**
**~៤០០ពាន់** កន្លែង

## ទុនវិនិយោគតាមវិស័យ (គិតជាដុល្លារអាម៉េរិក)




## ប្រភពទុនវិនិយោគឈានមុខ

| | | |
|---|---|---|
| 1. | ចិន | ៥២,៣៨% |
| 2. | កម្ពុជា | ៣២,៨៩% |
| 3. | សិង្ហបុរី | ៥,៩៧% |
| 4. | វៀតណាម | ៤,៤២% |
| 5. | កោះ British Virgin | ១,៦៩% |
| 6. | អង់គ្លេស | ០,៥៣% |
| 7. | សហរដ្ឋអាម៉េរិក | ០,៤៥% |
| 8. | កោះ Caymen | ០,៤៣% |
| 9. | កោះ Samoa | ០,៣៦% |
| 10. | ប៊ឺមុនដា | ០,២៨% |

## របាយគម្រោងវិនិយោគនៅតាមបណ្តារាជធានី-ខេត្ត

